# ថ្មចម្រូង
# ទីតាំងប្លែកមួយសម្រាប់ទេសចរណ៍ផ្សារភ្ជាប់ទឹកដី

ថ្មចម្រូងជាទីតាំងនៃបាតុភូតធម្មជាតិដ៏កម្រមួយកន្លែង ដែលស្ថិតនៅ ភូមិពូតាង ឃុំពូជ្រៃ ស្រុកពេជ្រជតា ខេត្តមណ្ឌលគិរី ក្នុងភូមិសាស្ត្រដែនជម្រកសត្វព្រៃភ្នំព្រេច មានចំនុចនិយាមការ X 710791 Y 1416968 មានកម្ពស់ ២៦៣ម ធៀបនិងនីវ៉ូទឹកសមុទ្រ (រូបលេខ១-២)។ ទីតាំងនេះ ជាទីតាំងដែលមានសក្តានុពលវិស័យទេសចរណ៍ធម្មជាតិផងដែរ (រូបលេខ៣-៤)។ តើទីតាំងនេះមានជំនឿយ៉ាងណា និងមានបាតុភូតយ៉ាងណា?

រឿងរ៉ាវខ្លះទាក់ទងនឹងថ្មចម្រូងមានដំណាលថា នៅភ្នំគង់ស្បាលពីដើមឡើយ ភ្នំនេះគឺជាភូមិមួយ ហើយភ្នំណាមរ៉ាមក៏ជាភូមិមួយ។ ថ្ងៃមួយមានកំលោះ ភូមិភ្នំគង់ស្បាល ទៅជំរិតយកកូនក្រមុំ នៅភូមិភ្នំណាមរ៉ាម ទុកធ្វើជាប្រពន្ធខ្លួន។ ហើយដោយសារខ្លាច អ្នកភូមិភ្នំណាមរ៉ាមដណ្តើមយកកូនក្រមុំយកទៅវិញ អ្នកភូមិភ្នំគង់ស្បាលក៏នាំគ្នា ធ្វើជញ្ជាំង និងចម្រូង ការពារភូមិរបស់ខ្លួន កុំឱ្យអ្នកភូមិភ្នំណាមរ៉ាមយកកូនក្រមុំវិញបាន។ ដោយសារតែសូគ្រាស ផងិតត្រជាក់ខ្លាំង ធ្វើឱ្យមនុស្ស នៅភូមិភ្នំគង់ស្បាល បានស្លាប់ ផ្ទះ ជញ្ជាំងការពារ និងចម្រូងត្រូវកករឹងទៅជាថ្មរហូតដូចសព្វថ្ងៃនេះទៅ នេះបើតាមចាស់ៗ និយាយតៗគ្នា។[១]

តំបន់ថ្មចម្រូង ជាបាតុភូតធម្មជាតិមួយ ដែលលេចចេញក្នុងបរិវេណប្រមាណ ២.៥ គីឡូម៉ែត្រ ហើយលេចចេញច្រើនក្នុងប្រហែល៥០០ម៉ែត្រលើកូនភ្នំមួយ។ ថ្មចម្រូងជាប្រភេទថ្មភក់ ដែលរាងជាសាជី មូលស្រួចទៅខាងលើ ខ្លះមានកម្ពស់រហូតដល់៨ម៉ែត្រ (រូបលេខ៥)។ តើបាតុភូតថ្មចម្រូងទាំងនេះកើតឡើងយ៉ាងដូចម្តេច?

ដំណាក់កាលទីមួយ កើតឡើងដោយការចាក់បង្គុំ ដោយស្រទាប់ខ្សាច់ និងល្បាប់ ជាស្រទាប់ផ្តេកៗ ត្រួតពីលើគ្នា តាំងពីរាប់រយលានឆ្នាំមកហើយ (រូបលេខ៦)។ ស្រទាប់ដីខ្សាច់ និងល្បាប់ ត្រួតលើគ្នាជាបន្តបន្ទាប់ ដោយសារសម្ពាត និងទំងន់ដ៏ធ្ងន់ និងដោយការប្រែប្រួលនៃធម្មជាតិ បានធ្វើឱ្យស្រទាប់ដីមួយចំនួនក្លាយទៅជាថ្មដែលប្រភេទថ្មនោះហៅ

[១] លោក ខាង សឿង ជាមន្ត្រីឧទ្យានុរក្ស ដែនជម្រកសត្វព្រៃស្រែពក និងជាជនជាតិព្នង

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

ថាថ្មភក់ (Sandstone)។ នៅក្នុងតំបន់នេះត្រូវបានកំណត់សំគាល់ T3-J1ss ថាមានកំណើតក្នុងអំឡុងសម័យកាល Triassic និងសម័យកាល Jurassic ដែលមានអាយុកាលចន្លោះ (២៦១ មក១៦១លានឆ្នាំ)។[២]

ដំណាក់កាលទី២ ស្រទាប់ថ្មភក់ទាំងនោះមានលក្ខណៈ ក៏បានទទួករងនៅបាតុភូតធម្មជាតិមួយចំនួនទៀតដូចជា បាតុភូតពំនើងផ្ទត់ អាចមានច្រើនដំណាក់កាល ឥទ្ធិពលនៃបន្ទុះភ្នំភ្លើង ដែលមាននៅខេត្តមណ្ឌលគិរី និងខ្លះនៅក្នុងខេត្តរតនគិរី ដូចជានៅបឹងលំកុដិ បឹងយ៉ាកអោយយ៉ាកកាវ៉ា បឹងយ៉ាកម៉ាយ ដែលនៅស្ថិតនៅប្រមាណ ៥០គីឡូម៉ែត្រពីតំបន់ទាំងនោះ។ ទាំងនេះសុទ្ធតែជាមូលហេតុដែលបានជម្រុញអោយតំបន់នេះមានការប្រែប្រួលពីតំបន់ដែលធ្លាប់នៅក្នុងសមុទ្រ ក្លាយជាតំបន់គោក[២] និងបានធ្វើស្រទាប់ថ្មភក់ដែលផ្តេកនោះទៅជាបញ្ឈិត និងពេលខ្លះអាចរុញទៅបញ្ឈរបាន។

ដំណាក់កាលទី៣ ស្រទាប់ថ្មភក់ដែលផ្តេកបានរុញទៅជាស្រទាប់បញ្ឈរ ហើយស្រទាប់ថ្មភក់នីមួយៗមានភាពរឹងមិនដូចគ្នាទេ។ ដូចជាជួរថ្ម នៃថ្មចម្រូងដែលលេចចេញជាថ្មចម្រូងនោះគឺជាផ្នែករឹង ចំណែកផ្នែកដែលផុយត្រូវបានហូរច្រោះដោយទឹក បង្កើតបានជាផ្ទៃដែលផត (រូបលេខ៧-៨)។

ដំណាក់កាលទី៤ យើងលើកយកពីថ្មមួយជួរមកពន្យល់ ថ្មនោះបានប្រេះជាពីរផ្នែកតាមផ្នែកបញ្ឈរ (រូបលេខ៩) បន្ទាប់មកក៏មានការប្រេះបែកជាចំណែកផ្សេងៗ ដោយកំដៅចេញជាបំណែកស្តើងៗ ដែលមានកម្រាស់ប្រមាណ២ស.មទៅ៥ស.ម បណ្តោយ៤០ ឬ ៥០ស.ម (រូបលេខ១០) ដែលអាចធ្វើអោយថ្មនោះកាន់តែបែកចេញបីគ្នា (រូបលេខ១១) រយៈពេលក្រោយមកក៏កើតបានជាថ្មចម្រូងដែលយើងឃើញនោះផងដែរ ថ្មខ្លះនៅតែបន្តប្រែប្រួល។ លក្ខណៈបែបនេះជាបាតុភូតដ៏កម្រមួយ ថ្វីត្បិតតែប្រភេទថ្មភក់មានច្រើនកន្លែងនៅប្រទេសកម្ពុជា។ តែការកកើតមិនដូចគ្នាទេ ដែលវាអាស្រ័យលើបំរែបម្រួលធម្មជាតិសាធាតុដែលមាននៅក្នុងថ្ម កំរិតរឹង ទីតាំងដែលកើតឡើង សុទ្ធតែអាចធ្វើអោយថ្មប្រភេទមួយមានលក្ខណៈមិនដូចគ្នា៕

[២] General Department of Mineral Resource, 2010, Geological Map of Cambodia

[២] https://ams.com.kh/khmercivilization/detail/1278

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ




រូបលេខ១ ផែនទី ទីតាំងថ្មចម្រូង ខេត្តបណ្ឌាលគិរី




រូបលេខ២ ថ្មចម្រូង បានលេចចេញប្រមាណ២.៥គ.ម

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័



រូបលេខ៣ ទិដ្ឋភាពនៃថ្មចម្រូង



រូបលេខ៤ ទិដ្ឋភាពនៃថ្មចម្រូង

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៥ ទិដ្ឋភាពនៃថ្មចម្រូង



រូបលេខ៦ ប្រភេទខ្លះនៃពពួកថ្មភក់ (ប្រភព Google)

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ២៧ លក្ខណៈនៃថ្មចម្រូង



រូបលេខ២៨ លក្ខណៈនៃថ្មចម្រូង

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័



រូបលេខ៩ ថ្មមួយបានប្រេះជាពីរ



រូបលេខ១០ ថ្មចម្រូង បែកជាផ្នែកតូចៗដោយសារកំដៅ

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ១១ ថ្មបែកជាពីរ បានបែកដោយកំដៅ រហូតក្លាយជាថ្មពីរ

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ